**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤៩៣...សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបន្តការងាររបស់គណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវយកទៅតាំងពិពណ៌នៅសាធារណរដ្ឋកូរ៉េ ប្រទេសជប៉ុន សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និង ប្រទេសអេស្ប៉ាញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានបន្តការងាររបស់គណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យលើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវបានខ្ចីយកទៅតាំងពិពណ៌ នៅសាធារណរដ្ឋកូរ៉េ ប្រទេសជប៉ុន សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងប្រទេសអេស្ប៉ាញ ដែលមានសមាសភាព ដូចតទៅ :

១- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាព្រះប្រធាន

២- ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៣- ឯកឧត្តម សេង លឹមនៅ រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៤- ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

៥- ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៧- ឯកឧត្តម យឹម សារិទ្ធ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៨- ឯកឧត្តម ទឹម ចាន់ដារ៉ា អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៩- ឯកឧត្តម ចី តាយី អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០- ឯកឧត្តម អ៊ុំ ខេង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកអចិន្ត្រៃយ៍ និងជា អគ្គលេខាធិការគណៈកម្មការ

១១- ឯកឧត្តម ស៊ឹម សួង អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

១២- ឯកឧត្តម បណ្ឌិត ប៉ែន ដារេន ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣- លោកជំទាវ តាន់ ចានី អគ្គលេខាធិការគណៈកម្មការជាតិយូណេស្កូ សមាជិក

១៤- ឯកឧត្តម បណ្ឌិត ក្រាញ់ ច័យលាភី ទូនី អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៥- ឯកឧត្តម រស់ បូរ៉ាត អគ្គនាយករងអាជ្ញាធរអប្សរា ទទួលបន្ទុកការងាររមណីយដ្ឋាន និងបុរាណវិទ្យា សមាជិក

១៦- ឯកឧត្តម ទុយ តៀន សាកលវិទ្យាធិការ សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សមាជិក

១៧- ឯកឧត្តម ទឹម វិសិដ្ឋ ប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៨- លោក សួស យ៉ារ៉ា អគ្គលេខាធិការ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា សមាជិក

១៩- លោក ខេង កែវ អគ្គនាយករងបច្ចេកទេស ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

២០- លោក អ៊ួង វន ប្រធាននាយកដ្ឋានបេតិកភណ្ឌវប្បធម៌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

២១- លោក ឃុន សាមេន ប្រធាននាយកដ្ឋាន សារមន្ទីរ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្ប សមាជិក

២២- លោក ចង់ អ្នក ប្រធាននាយកដ្ឋាន សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងសិទ្ធមនុស្ស ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

២៣- លោក ឡាយ ណារុឌ្ឍ អនុប្រធាននាយកដ្ឋានស្ថាបនា ក្រសួងមហាផ្ទៃ សមាជិក

២៤- លោក សុក សារ៉េត អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ក្រសួងមហាផ្ទៃ សមាជិក

ប្រការ ២.-

គណៈកម្មការនេះមានភារៈកិច្ចធ្វើការទំនាក់ទំនង នឹងក្រសួងពាក់ព័ន្ធនានា និងសាធារណៈរដ្ឋកូរ៉េ ប្រទេសជប៉ុន សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងប្រទេសអេស្ប៉ាញ ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យលើវត្ថុបុរាណសិល្បៈខ្មែរ សំរាប់ទៅតាំងពិពណ៌ នៅតាមប្រទេសនិមួយៗ ។

ប្រការ ៣.–

អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសេនាធិការ របស់អគ្គលេខាធិការ ។

ប្រការ ៤.–

សេចក្តីសំរេចនេះ គ្របដណ្តប់លើសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល

- លេខ ៥៣ ស.ស.រ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីវាយតម្លៃ និងត្រួតពិនិត្យវត្ថុបុរាណសិល្បៈខ្មែរ ដែលក្រុមហ៊ុន TOEI ប្រទេសជប៉ុន ខ្ចីយកទៅតាំងពិពណ៌នៅប្រទេសជប៉ុន រយៈពេលមួយឆ្នាំ ចាប់ពីខែ កញ្ញា ឆ្នាំ ២០០៤
- លេខ ០៥ ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលក្រុមហ៊ុន TOEI ជប៉ុន ខ្ចីយកទៅតាំងពិពណ៌នៅប្រទេសជប៉ុន រយៈពេល ១៤ ខែ ចាប់ពីខែ មិថុនា ឆ្នាំ ២០០៥ ដល់ខែ កក្កដា ឆ្នាំ ២០០៦ និងសារមន្ទីរសិល្បៈ និងមហោស្រពពិពណ៌ នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ខ្ចីយកទៅតាំងពិពណ៌នៅទីក្រុងបោន សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ រយៈពេល ៦ ខែ ឆ្នាំ ២០០៦-២០០៧
- លេខ ១៦ ស.ស.រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការបន្ថែមភារៈកិច្ច និងសមាជិកគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវខ្ចីយកទៅតាំងពិពណ៌ នៅប្រទេស ជប៉ុន សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសាធារណរដ្ឋកូរ៉េ

ប្រការ ៥.–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរអប្សរា អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ ដែលបានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ_កាលប្បវត្តិ